# ៥. ភាពចំរុះផ្សេងគ្នាវប្បធម៌ចំរុះគ្នា ភាសាផ្សេងៗនៅក្នុងតំបន់ទន្លេមេគង្គ



វិហាមូននៅខេត្តវ៉ាត់ឆាប្ជូរីភាគខាងលិចប្រទេសថៃ (ខែកញ្ញាឆ្នាំ២០១២)

ភាសាសរុបទាំងអស់មាន៣៩៨ភាសាត្រូវបាននិយាយក្នុងប្រទេសមេគង្គទាំង៥ (ភូមាឡាវថៃកម្ពុជាវៀតណាម)[1]។ចំនួននេះស្មើនឹង៥.៨% នៃចំនួនភាសាសរុប៦,៩០៩ដែលបានចុះបញ្ជីរាយឈ្មោះភាសាពិភពលោកEthnologue។ម្យ៉ាងទៀតចំនួនអ្នកនិយាយភាសាក្នុងប្រទេសទាំង៥នេះគឺមាន៣.២%នៃពិភពលោក ដូច្នេះមានន័យថា៣.២%នៃអ្នកនិយាយភាសា៥.៨%នៃភាសាទាំងអស់ក្នុងពិភពលោក។វាធ្លាក់ចុះទាបនៃតំបន់ប៉ាស៊ីហ្វិក (០.១% នៃអ្នកនិយាយភាសា១៨.១%នៃភាសា) ហើយតំបន់ទ្វីបអាមេរិកខាងជើងនិងខាងត្បូង (០.៨%នៃអ្នកនិយាយភាសា១៤.៤%នៃភាសា) ប៉ុន្តែបើប្រៀបធៀបជាមួយអឺរ៉ុប (២៦.១%នៃអ្នកនិយាយភាសា៣.៤%នៃភាសា) ឬអាស៊ីទាំងមូល (៦០.៨%នៃអ្នកនិយាយភាសា៣៣.៦%ភាសា) វាអាចនិយាយបានថាមានភាសាផ្សេងៗចំរុះបែបយ៉ាងក្នុងចំណោមចំនួនប្រជាជនក្នុងតំបន់ទន្លេមេគង្គ[2]។

| ប្រទេស | # អ្នកនិយាយ ភាសា | # ភាសា | ភាសាមានអ្នកនិយាយតិចជាង ១០,០០០នាក់ | ឧទាហរណ៍ |
|---|---|---|---|---|
| កម្ពុជា | ១៣,៥១១,៩៧០ | ២៣ | ១២ | ព្រៅ,សំរែ,ស្អូច |
| ឡាវ | ៥,៣៤៩,៨៩៤ | ៨៤ | ៤៧ | អាហ៊ី,អារ៉ែម,ឆុត |
| ភូមា | ៤៧,៣១៩,៨០០ | ១១១ | ៣៥ | អានុ,តាវឆិន,ហ្គួន |
| ថៃ | ៥១,៦៦៨,៩៩៧ | ៧៤ | ២៨ | ប៊ីសុ,ឆុង,ផ្លង់ |
| វៀតណាម | ៧៥,៦៥០,០៩៩ | ១០៦ | ៤២ | អារ៉ែម,ឆុត,អន |
| សរុប (៥ប្រទេស) | ១៩៣,៥០០,៧៦០ | ៣៩៨ | ១៦៤ | |
| ពិភពលោកសរុប | ៥,៩៥៩,៥១១,៧១៧ | ៦,៩០៩ | ៣,៥២៤ | |
| ភាគរយ | ៣.២% | ៥.៨% | | |

[1]យោងតាមចំនួនបានផ្តល់ក្នុងបញ្ជីរាយឈ្មោះភាសាក្នុងពិភពលោកEthnologue (Lewis 2009)

[2]ក្នុងទ្វីបអាហ្វ្រិក១២.២%នៃអ្នកនិយាយភាសា ប្រើប្រាស់៣០.៥%នៃភាសាក្នុងពិភពលោក

## ភាសានៅក្នុងប្រទេសទាំង៥ក្នុងតំបន់ទន្លេមេគង្គ

ក្នុងចំណោម៣៩៨ភាសាចំនួនភាសា១៦៤ (៤១.២%) មានអ្នកនិយាយតិចជាង១០ពាន់នាក់[3]។ខណៈការរស់រាននៃភាសាមិនមែនត្រូវបានសំរេចដោយចំនួនអ្នកនិយាយទាំងស្រុងទេ(NettleនិងRomaine២០០០) បន្ទាប់ពីធ្វើការគណនាចេញពីការពិនិត្យប្រៀបធៀប(Crystal២០០០) ប៉ាន់ប្រមាណថា៥០%នៃភាសានឹងបាត់បង់ក្នុងពេល១០០ឆ្នាំខាងមុខនិងភាគរយនៃភាសាក្នុងពិភពលោកដែលមានអ្នកនិយាយតិចជាង១០ពាន់នាក់គឺមានចំនួនពិតប្រាកដ៥១.០% (៣,៥២៤ភាសា)។ដូច្នេះវាមានជំរើសខ្ពស់ដែលថាមាន១៦៤ភាសាត្រូវបាននិយាយដោយជនជាតិដើមភាគតិចនិងជនជាតិភាគតិចនៅក្នុងតំបន់ទន្លេមេគង្គហើយនឹងបាត់បង់ក្នុងកំលុងសតវត្សរ៍ទី២១។ការគណនាការបាត់បង់គឺ១ឬ២ភាសាជារៀងរាល់ឆ្នាំក្នុងប្រទេសទាំង៥តាមបណ្ដោយទន្លេមេគង្គ។ភាសាបានបន្តបាត់បង់និងវិវឌ្ឍតាមរយៈប្រវត្តិសាស្រ្តមនុស្សជាតិប៉ុន្តែ  អត្រានៃការរលត់សាបសូន្យបានកើនឡើងយ៉ាងខ្លាំងក្នុងរយៈពេលជាង៥០០ឆ្នាំកន្លងហើយនេះជាការគួរបារម្ភ (NettleនិងRomaine ២០០០)។

## តើអ្វីជាការគំរាមកំហែងដល់ភាសាភាគតិច?

កត្តាគំរាមកំហែងដល់ភាសាភាគតិចដ៏ធំបំផុតក្នុងតំបន់ទន្លេមេគង្គគឺកើនឡើងយ៉ាងឆាប់រហ័សនៃភាសាធំៗដូចជាភាសាជាតិនិងភាសាផ្លូវការនានា។ពិសេសការអប់រំសាធារណៈលើកទឹកចិត្តឬសូម្បីតែតម្រូវប្រើប្រាស់និងទទួលយកភាសាធំៗ។ខណៈកុមារនៃក្រុមជនជាតិភាគតិចត្រូវការរៀនភាសាជាតិនិងភាសាផ្លូវការហើយពួកគេមានសិទ្ធិធ្វើដូច្នោះវាជាបញ្ហាដែលគ្រូបង្រៀននិងឪពុកម្ដាយត្រូវបើកចំហរឬបើកចំហរដោយព្យាយាមរាំងខ្ទប់ឲ្យប្រើប្រាស់ភាសាភាគតិចទាំងនោះ។នេះនាំឲ្យកុមារមានសំណួរអំពីតម្លៃនៃដើមកំណើតនិងការអប់រំរបស់ពួកគេ។ជាលទ្ធផលភាសាភាគតិចមិនត្រូវបានយកមកប្រើនៅក្នុងសាលារៀនហើយសូម្បីតែនៅតាមផ្ទះដូច្នេះភាសាមិនត្រូវបាន



ស្ត្រីជនជាតិខមុក្នុងស្រុកប៉ាក់បេង, ខេត្តឧត្តមសៃនៅភាគខាងត្បូងប្រទេសឡាវ

---

[3]Nettle (1999) រាយការណ៍ថា ភាគរយនៃភាសាទាំងអស់ មានអ្នកនិយាយតិចជាង១០,០០០នាក់ ត្រូវជា៩២.៨% ក្នុងតំបន់អូស្ត្រាលី /អូសេអានី ៧៦.៥%ក្នុងអាមេរិកខាងត្បូង ៧៧.៨%ក្នុងអាមេរិកខាងជើង ៣៦.៤%ក្នុងអាមេរិកកណ្ដាល ៣២.៦%ក្នុងអាហ្វ្រិក និង ៣០.២%ក្នុងអឺរ៉ុប ។ ទូទាំងសាកលជាមធ្យមគឺ ៥៩.៤% និងជាមធ្យមក្នុងអាស៊ីគឺ៥២.៨% ។

ចែកចាយដល់មនុស្សជំនាន់ក្រោយ។លើសពីនោះទៀតភាសាធំៗបានពង្រីកនិងមានឥទ្ធិពលតាមរយៈទូរទស្សន៍វិទ្យុកាសែតនិងប្រព័ន្ធផ្សព្វផ្សាយធំផ្សេងៗក៏ដូចជាវប្បធ៌មប្រជាប្រិយក្នុងខ្សែភាពយន្តនិងចំរៀង។បន្ថែមជាងនេះទៀតភាសាអង់គ្លេសដើរតួរជាភាសា«អន្តរជាតិ»សំរាប់ការទំនាក់ទំនងក្នុងតំបន់ទន្លេមេគង្គជាមួយការបញ្ចូលប្រទេសអាស៊ានដែលនឹងមកដល់ក្នុងឆ្នាំ២០១៥ជាការជំរុញឱកាសបាត់បង់ការឲ្យតម្លៃភាសាភាគតិចថែមទៀត។

ជម្លោះនិងសង្គ្រាមស៊ីវិលគ្រោះធម្មជាតិរោគរាតត្បាតនិង (ការបង្ខំ)ផ្លាស់ប្តូរទីលំនៅដោយសារគំរោងអភិវឌ្ឍធំៗដូចជាការសាងសង់ទំនប់គឺជាការគំរាមកំហែងដល់ភាពរស់រានរបស់ភាសាភាគតិចផងដែរ។អ្នកនិយាយភាសាមងជាជនជាតិដើមភាគតិចរស់នៅក្នុងភាគខាងត្បូងប្រទេសភូមានិងថៃបានរងគ្រោះរញ្ជួយផែនដីនិងស៊ូណាមិយ៉ាងខ្លាំងក្នុងខែធ្នូឆ្នាំ២០០៤។ពីមុននោះពួកគេមានស្ថានភាពសេដ្ឋកិច្ចនិងសង្គមអន់ថយរួចទៅហើយប៉ុន្តែអ្នកនិយាយភាសាមងជាពិសេសអ្នករស់នៅតាមឆ្នេរសមុទ្រពួកគេបានបាត់បង់ទូកនិងផ្ទះទៅតាមស៊ូណាមិដែលគឺជាការប្រឈមជាមួយវិបត្តិ (Skehan២០១២) ។ភូមិដែលមានអ្នកនិយាយភាសាអ៊ូគុងជាភាសាមានដើមកំណើតពីភាសាស៊ីណូ-ទីបេរស់នៅក្នុងតំបន់ខាងលិចប្រទេសថៃត្រូវបានអាជ្ញាធរ អគ្គិសនីថៃបង្ខំឲ្យរើលំនៅឋានដើម្បីសាងសង់ទំនប់។ជាលទ្ធផលការរួបរួមនៅក្នុងសហគមន៍មានភាពទន់ខ្សោយបង្កើនជាឧបសគ្គក្នុងការថែរក្សាភាសានិងអត្តសញ្ញាណថែមទៀត (Bradley១៩៨៩)។



ស្ត្រីជនជាតិយ៉ាហឿនតាមតំបន់តន្លេសេកុង ភាគខាងត្បូងប្រទេសឡាវ

ភាសារបស់ជនជាតិដើមភាគតិចនិងជនជាតិភាគតិចបានបំពេញគតិបណ្ឌិតនិងចំណេះដឹងប្រមូលផ្តុំតាមរយៈរបៀបរស់នៅជាប្រពៃណីនិងការរស់នៅបែបធម្មជាតិ។មានអ្នកស្រាវជ្រាវខ្លះបាននិយាយថាមនុស្សកើតមកជាមួយភាសានិងវប្បធ៌ម( McCarty, Skutnabb-KangasនិងMagga២០០៧) ។

**ឯកសារយោង:**

Bradley, David. 1989. The Disappearance of the Ugong in Thailand. In Nancy Dorian (ed.) *Investigating Obsolescence: Studies in Language Contraction and Death.* Cambridge, UK: Cambridge University Press 33-40.

Crystal, David. 2000. *Language Death*. Cambridge, UK: Cambridge University Press.

Lewis, M. Paul (ed.) 2009. *Ethnologue: Languages of the World, 16th Edition*. Dallas, Texas: SIL International.

http://www.ethnologue.com/
McCarty, Teresa L., Tove Skutnabb-Kangas, and Ole Henrik Magga. 2007. Education for Speakers of Endangered Languages. In *Handbook of Educational Linguistics*.Oxford, UK: Oxford University Press 297-311.
Nettle, Daniel. 1999. *Linguistic Diversity*. Oxford, UK: Oxford University Press.
Nettle, Daniel, and Suzanne Romaine. 2000. *Vanishing Voices: The Extinction of the World's Languages.* Oxford: UK, Oxford University Press.
Skehan, Craig. 2012. Time Running out for Moken Way of Life. *Bangkok Post* May 13, 2012. http://www.bangkokpost.com/news/investigation/293059/time-running-out-for-moken-way-of-life

ឱយទុហ្សិយូគិ